ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការគ្រប់គ្រងរមណីយដ្ឋាន ប្រាសាទព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៥ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានឃើញអនុក្រឹត្យលេខ ៨៩/អនក្រ/បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការអនុវត្តកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការចំរុះរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការគ្រប់គ្រងរមណីយដ្ឋាន ប្រាសាទព្រះវិហារ ដែលមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ឌី យ៉ាង | អនុប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ប្រធាន |
| ២- | តំណាងគណៈកម្មការបច្ចេកទេសព្រំដែន | | | អនុប្រធាន |
| ៣- | ឯកឧត្តម | ជុំច គឿន | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- | ឯកឧត្តម | ឆាន់ សាផាន | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥- | ឯកឧត្តម | ធ្មី សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦- | ឯកឧត្តម | រស់ ផេន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- | ឯកឧត្តម | ថ្លាង ស៊ុន | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- | ឯកឧត្តម | នីយ យឿន | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | សមាជិក |
| ៩- | ឯកឧត្តម | រស់ បូរ៉ាត | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១០- | ឯកឧត្តម | អ៊ុក សុមេត្ត | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១១ | ឯកឧត្តម | ពេជ កែវ | សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ១២- | ឯកឧត្តម | មួន លឹមហេង | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣- | លោកជំទាវ | តាន់ ធានី | អគ្គលេខាធិការគណៈកម្មការជាតិសម្រាប់យូណេស្កូ | សមាជិកអចិន្ត្រៃយ៍ |
| ១៤- | ឯកឧត្តម | ថ្វាច តាន់ | អភិបាលខេត្តព្រះវិហារ | សមាជិក |
| ១៥- | លោក | អ៊ុត សេដ្ឋា | ប្រធាននាយកដ្ឋានភូមិសាស្ត្រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៦- | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ព្រះវិហារ | | | សមាជិក |
| ១៧- | លោក | សូ ឡៅង | អនុប្រធានការិយាល័យបុរាណវិទ្យា នៃអាជ្ញាធរអប្សរា | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច ដូចតទៅ :

ក- ចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែង ពិនិត្យនូវសភាពការណ៍បច្ចុប្បន្ន ស្វែងយល់ពីការប្រែប្រួល និងមូលហេតុដែលប្លែកពីសភាពដើមរបស់រមណីយដ្ឋានប្រាសាទព្រះវិហារ សំខាន់យកចិត្តទុកដាក់លើតំបន់ស្នូល (តំបន់ទី១) និងតំបន់ទ្រនាប់ (តំបន់ទី២)

ខ- ចងក្រងនូវរាល់លិខិតបទដ្ឋានគតិយុត្ត ដោយលើកនូវរាល់វិធានការចាំបាច់ សំដៅថែរក្សា ការពារ និងគ្រប់គ្រងនូវរាល់សម្បត្តិវប្បធម៌បុរាណ ប្រវត្តិសាស្ត្រ និងសម្បត្តិធម្មជាតិ

គ- លើកកម្ពស់ថែមទៀតនូវតម្លៃសម្បត្តិវប្បធម៌បុរាណ ប្រវត្តិសាស្ត្រ និងសម្បត្តិធម្មជាតិតាមតំបន់ការពារនីមួយ ១ ក្រោមរូបភាពការអភិរក្ស និងការអភិវឌ្ឍរមណីយដ្ឋានប្រាសាទព្រះវិហារ

ឃ- ក្នុងពេលអនុវត្ត បើជួបបញ្ហាលំបាកហួសពីសមត្ថកិច្ចរបស់ខ្លួន គណៈកម្មការត្រូវស្នើសុំយោបល់ និងមតិណែនាំពីរាជរដ្ឋាភិបាល

ង- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជាបន្តបន្ទាប់ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** គណៈកម្មការ មានទីស្នាក់ការអចិន្ត្រៃយ៍ស្ថិតនៅអគ្គលេខាធិការដ្ឋាននៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៤ :** សមាជិកគណៈកម្មការត្រូវអញ្ជើញចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្ដីការគណៈរដ្ឋមន្ត្រីសម្រាប់សម្រួលការងារ ។

**ប្រការ ៥ :** គណៈកម្មការ មានកញ្ចប់ថវិកាដោយឡែកដែលស្ថិតនៅក្នុងថវិកា សរុបរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ប្រធានអាជ្ញាធរអប្សរា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានគណៈកម្មការជាតិសម្រាប់យូណេស្កូ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដី សម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ